# ឱសថស្ថាន Supercare រដ្ឋវិចថូរៀ

Victorian Supercare Pharmacies - Khmer | ភាសាខ្មែរ

**OFFICIAL**

ឱសថស្ថាន Supercare រដ្ឋវិចថូរៀ ត្រូវបានគាំទ្រដោយរដ្ឋាភិបាលរដ្ឋវិចថូរៀ ដើម្បីផ្តល់នូវលទ្ធភាពចូលប្រើប្រាស់ការថែទាំសុខភាព និងជំបូន្មានប្រកបដោយវិជ្ជាជីវៈក្រោយម៉ោងធ្វើការ។

ឱសថស្ថាន Supercare៖

- បើកធ្វើការ 24 ម៉ោងក្នុងមួយថ្ងៃ ប្រាំពីរថ្ងៃក្នុងមួយសប្តាហ៍ ដោយផ្តល់នូវលទ្ធភាពចូលប្រើប្រាស់ឱសថការីសម្រាប់ជំបូន្មានការផ្គត់ផ្គង់ថ្នាំ និងការចេញវេជ្ជបញ្ជា។
- រួមបញ្ចូលទាំងសេវាកម្មគិលានុបដ្ឋាកដោយឥតគិតថ្លៃនៅរវាងម៉ោង 6 ល្ងាច ដល់ម៉ោង 10 យប់ ជារៀងរាល់ថ្ងៃសម្រាប់ជំងឺ និងរបួសតិចតួច ដោយប្រើបន្ទប់ពិគ្រោះឯកជន។
- ដំណើរការក្រោមឈ្មោះ និងម៉ាកយីហោឱសថស្ថានដែលបានសម្រាំងជ្រើសរើស ដើម្បីផ្តល់ជូនសេវាកម្មបន្ថែមនេះនៅក្នុងសហគមន៍របស់អ្នក។ ឱសថស្ថានទាំងនេះត្រូវបានគាំទ្រដោយរដ្ឋាភិបាលដើម្បីបើកធ្វើការ 24 ម៉ោង 7 ថ្ងៃក្នុងមួយសប្តាហ៍ ហើយមានបន្ទប់ពិគ្រោះឯកជនដោយឡែកពិសេសសម្រាប់គិលានុបដ្ឋាក ដើម្បីធានានូវភាពឯកជនក្នុងអំឡុងពេលអញ្ជើញទៅពិនិត្យរបស់អ្នក។
- គោរពភាពឯកជនរបស់អ្នក។ ព័ត៌មានសុខភាពរបស់អ្នកនឹងត្រូវបានចែករំលែក ដោយមានការយល់ព្រមពីអ្នក និងសម្រាប់គោលបំណងជាក់លាក់បំផុត រួមទាំងជាមួយវេជ្ជបណ្ឌិតធម្មតារបស់អ្នកតែប៉ុណ្ណោះ។
- មានលទ្ធភាពចូលប្រើប្រាស់សេវាកម្មអ្នកបកប្រែផ្ទាល់មាត់។
- មានអ្នកយាមសន្តិសុខនៅនឹងកន្លែងនៅពេលយប់ ហើយប្រសិនបើស្ថានភាពតម្រូវ នឹងមានការចូលរួមពីសេវាកម្មសង្គ្រោះបន្ទាន់ដែលសមស្រប។
- មានស្តុកឱសថថែទាំសម្រាលការឈឺចាប់តាមស្តង់ដារ។

# ឱសថការី Supercare

- មានផ្តល់ជូនឱសថការី Supercare 24 ម៉ោងក្នុងមួយថ្ងៃ ប្រាំពីរថ្ងៃក្នុងមួយសប្តាហ៍ សម្រាប់ការចេញវេជ្ជបញ្ជា រួមជាមួយនឹងការផ្តល់ឱសថតាមបញ្ជារ សម្រាប់ការព្យាបាលដោយខ្លួនឯង។
- ឱសថការី Supercare ក៏អាចផ្តល់ជូនដំបូន្មាន និងការគាំទ្រផ្នែកថែទាំសុខភាពបឋម រួមជាមួយនឹងការអប់រំជុំវិញការលើកកម្ពស់សុខភាព ការបង្ការជំងឺ និងការប្រើប្រាស់ថ្នាំពេទ្យត្រឹមត្រូវផងដែរ។

# សេវាកម្មគិលានុបដ្ឋាក Supercare

- មានផ្តល់ជូនគិលានុបដ្ឋាកដែលបានចុះបញ្ជីស្របច្បាប់ សម្រាប់ការពិគ្រោះយោបល់ជារៀងរាល់យប់ រវាងម៉ោង 6 ល្ងាច ដល់ម៉ោង 10 យប់។
- គិលានុបដ្ឋាយកអាចវាយតម្លៃ និងព្យាបាលអ្នកណាម្នាក់ដែលមានបញ្ហាសុខភាពតិចតួចដូចជាកន្ទួលស្បែក គ្រុនក្តៅ និងសត្វល្អិតខាំ ព្រមទាំងព្យាបាលការរលាក ស្នាមកាត់ និងស្នាមជាំតិចតួច។ ពួកគេក៏នឹងអាចពិនិត្យសម្ពាធឈាម ចាក់ថ្នាំបង្ការរោគ និងផ្តល់ជូនដំបូន្មានអំពីរបៀបរស់នៅ និងព័ត៌មានសុខភាពផងដែរ។
- គិលានុបដ្ឋាកអាចមានផ្តល់ជូនដើម្បីចាត់ចែងការចាក់ថ្នាំបង្ការរោគមួយចំនួន ដូចជាការចាក់វ៉ាក់សាំងរោគក្អកមាន់ និង គ្រុនផ្តាសាយ។ ពួកគេក៏អាចចាត់ចែងការចាក់ថ្នាំបង្ការរោគតាមវេជ្ជបញ្ជារបស់វេជ្ជបណ្ឌិតផងដែរ។
- គិលានុបដ្ឋាកដែលបម្រើក្នុងឱសថស្ថាន Supercare មិនអាចចេញវេជ្ជបញ្ជាបានទេ។ ប្រសិនបើមានការទាមទារពិនិត្យឡើងវិញផ្នែកវេជ្ជសាស្ត្រ គិលានុបដ្ឋាកនឹងណែនាំទៅកាន់អ្នកផ្តល់សេវាកម្មសុខភាពសមស្របផ្សេងទៀត។
- មិនចាំបាច់ការណាត់ពេលជួបទេ។ អ្នកជំងឺត្រូវបានគេពិនិត្យតាមមូលដ្ឋានមកដល់មុន នឹងត្រូវបានពិនិត្យមុន។ ប្រសិនបើស្ថានភាពរបស់បុគ្គលនោះត្រូវការការថែទាំកម្រិតខ្ពស់ ពួកគេត្រូវបានបញ្ជូនទៅកាន់សេវាថែកម្មទាំសុខភាពដែលសមស្របជាង។
- គ្មានការគិតថ្លៃលើការពិគ្រោះយោបល់ដើម្បីទៅជួបគិលានុបដ្ឋាកនៅឱសថស្ថាន Supercare ទេ។ ការផ្គត់ផ្គង់ផ្នែកវេជ្ជសាស្ត្រដែលគិលានុបដ្ឋាកប្រើប្រាស់ក្នុងអំឡុងពេលពិគ្រោះយោបល់ ក៏ឥតគិតថ្លៃផងដែរ។ អ្នកជំងឺអាចជ្រើសរើសទិញផលិតផលបន្ថែមពីឱសថស្ថានក៏បានដែរ។
- អ្នកមិនចាំបាច់ត្រូវការប័ណ្ណ Medicare ទេ។ សេវាកម្មនេះមានសម្រាប់ពលរដ្ឋវិចថូរៀ និងអ្នកមកទស្សនារដ្ឋនេះគ្រប់រូប។
- ក្នុងករណីខ្លះ ទម្រង់ព្យាបាលដែលសមស្របបំផុត អាចមានពីវេជ្ជបណ្ឌិតព្យាលបាលរោគទូទៅ។ គិលានុបដ្ឋាកអាចណែនាំឱ្យអ្នកទៅជួប GP ទៀងទាត់របស់អ្នក ពេលណា GP នៅបម្រើការ។ គិលានុបដ្ឋាកឱសថស្ថាន Supercare អាចណែនាំអ្នកទៅកាន់សេវាកម្មក្រោយម៉ោងធ្វើការក្នុងតំបន់ សេវាកម្មវេជ្ជសាស្ត្រផ្សេងទៀត ឬអាចណែនាំអ្នកឱ្យអញ្ជើញទៅ ED។ ដោយមានការយល់ព្រមពីអ្នក គិលានុបដ្ឋាកនឹងផ្តល់សេចក្តីសង្ខេបជាលាយលក្ខណ៍អក្សរជូនវេជ្ជបណ្ឌិតរបស់អ្នក ជាមួយនឹងព័ត៌មានលម្អិតអំពីហេតុផលនានាដែលអ្នកបានអញ្ជើញទៅឱសថស្ថាន Supercare។

# ទីតាំងនានា

មានឱសថស្ថាន Supercare ចំនួន 20 កន្លែង បើកនៅពេញទូទាំងរដ្ឋវិចថូរៀ មានប្រាំមួយកន្លែងមានទីតាំងនៅក្នុងតំបន់នានា៖

- Ascot Vale - Ascot Vale Pharmacy, 67-69 Union Road, Ascot Vale, 9370 4146
- Ballarat - UFS Dispensaries, 717 Sturt Street, Ballarat, 5331 9811
- Balwyn - Balwyn Day and Night Pharmacy, 310-314 Whitehorse Rd, Balwyn, 9836 3245
- Bendigo - Bendigo UFS Pharmacies, Corner View and Barnard Streets, Bendigo, 5443 4610
- Coburg - Coburg Pharmacy 4 Less, 1 Louisa St, Coburg, 9386 6655
- Craigieburn - Chemist Discount Centre, 2A/340 Craigieburn Road, Craigieburn, 9308 4981
- Cranbourne North - Cranbourne North Chemist Warehouse, 180S William Thwaites Blvd, Cranbourne North, 8391 9509
- Curlewis - Curlewis Pharmacy 4 Less, 10-11/90 Centennial Blvd, Curlewis, 5251 6781
- Hoppers Crossing - Hoppers Crossing Chemist Warehouse, Shop 24-25, 428 Old Geelong Rd, Hoppers Crossing, 9931 0040
- Keilor East - Keilor East Chemist Warehouse, Lot 3 233 Milleara Rd, Keilor East, 9325 4660
- Keysborough - Parkmore Pharmacy 4 Less, Shop J01, 317 Cheltenham Rd, Keysborough, 9798 1936
- Melbourne - HealthSmart Pharmacy Victorian Comprehensive Cancer Centre, 311 Grattan St, Melbourne, 9045 9777
- Melton - Melton Chemist Warehouse, Unit 4 Melton Gateway, 66-84 High St, Melton, 9746 8733
- Mildura - Mildura Chemist Warehouse, 114A -118 Langtree Ave, Mildura, 5023 2383
- Reservoir - Reservoir Pharmacy 4 Less, Summerhill Shopping Centre, 27/850 Plenty Rd, Reservoir, 9471 0222
- Ringwood - Ringwood Chemist Warehouse, 131-133 Maroondah Hwy, Ringwood, 9870 5022
- Shepparton - Shepparton Chemist Warehouse, 425 Wyndham St, Shepparton, 5821 6000
- Traralgon - Traralgon Chemist Warehouse, 92 Franklin St, Traralgon, 5174 2003
- Wantirna South - Pharmacy@Knox, Shop 2081 Westfield Knox, 425 Burwood Hwy, Wantirna South, 9800 5199
- Yarraville - Carnovale Pharmacy, 149 Somerville Road, Yarraville, 9314 7557

To receive this document in another format, phone 1300 650 172, using the National Relay Service 13 36 77 if required. Or email Primary, Community and Oral Health Unit, Supercare Pharmacies<supercarepharmacies@health.vic.gov.au>.

Authorised and published by the Victorian Government, 1 Treasury Place, Melbourne.

© State of Victoria, Australia, Department of Health, December 2021.

Available at Better Health Channel <https://www.betterhealth.vic.gov.au/health/servicesandsupport/victorian-supercare-pharmacies>